# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៧០០៨ ព.ណ.អ.វ.ឯ

ថ្ងៃអង្គារ ១៤ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២០

## សេចក្តីជូនដំណឹង
### ស្តីពី
### ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់ ១៥ ខែកញ្ញា ឆ្នាំ២០២០ នឹងត្រូវលក់ ៣.២៣៧រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៩៣២រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់ ១៥ ខែកញ្ញា ឆ្នាំ២០២០** នឹងចុះមក ៣.០៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ២.៧៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | 0,៣០១៣ ដុល្លារ | 0,៣១០៤ ដុល្លារ |
| ២ | ពន្ធ៖ | 0,១៧៩១ ដុល្លារ | 0,០៦៩៦ ដុល្លារ |
| | ពន្ធគយ | 0,០៧២៦ ដុល្លារ | 0,0000 ដុល្លារ |
| | អាករបន្ថែម | 0,0២00 ដុល្លារ | 0,0៤00 ដុល្លារ |
| | អាករពិសេស | 0,០៨៦៥ ដុល្លារ | 0,០២៩៦ ដុល្លារ |
| ៣ | PREMIUM | 0,២0 ដុល្លារ | 0,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | 0,០៦៨០ ដុល្លារ | 0,០៦១០ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៧៤៨៥ ដុល្លារ | 0,៦៧១០ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.០៧២ រៀល | ២.៧៥៤ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៧៤ ដុល្លារ | 0,៦៧ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.០៥០ រៀល | ២.៧៥០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ដែលស្មើនឹង៤.១០៥រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៧ សីហា ២០២០ | ៤៧,៣១ | ៤៩,៣៤ |
| ១៨ សីហា ២០២០ | ៤៨,០១ | ៤៩,៦២ |
| ១៩ សីហា ២០២០ | ៤៧,៥០ | ៤៩,៧៩ |
| ២០ សីហា ២០២០ | ៤៧,៦៦ | ៤៩,២០ |
| ២១ សីហា ២០២០ | ៤៧,៧៩ | ៤៨,៩៧ |
| ២៤ សីហា ២០២០ | ៤៧,៧៦ | ៤៩,០៧ |
| ២៥ សីហា ២០២០ | ៤៨,៤៥ | ៤៩,៧២ |
| ២៦ សីហា ២០២០ | ៤៨,៣៤ | ៤៩,៩៦ |
| ២៧ សីហា ២០២០ | ៤៨,៦៥ | ៤៩,៥១ |
| ២៨ សីហា ២០២០ | ៤៦,៨០ | ៤៨,១០ |
| ៣១ សីហា ២០២០ | ៤៨,៦៥ | ៤៩,៥៥ |
| **មធ្យមភាគ ១១ថ្ងៃ** | **៤៧,៩០១៨** | **៤៩,៣៤៨២** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៣០១៣** | **០,៣១០៤** |

**ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ខែមិថុនា ដល់ ០១ ខែកញ្ញា ឆ្នាំ២០២០**




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។/.